00284519

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

D55/I/13

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៦)

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២៥ កុម្ភៈ ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 02 / 2009
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

សាធារណៈ

**សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញ**

---

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**<u>ជនត្រូវចោទ</u>**

នួន ជា

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN

**<u>សហមេធាវីការពារក្តី</u>**

សុន អារុណ
Michael PESTMAN
Victor KOPPE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

00284520

D55/I/13

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៦)

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** "អ.វ.ត.ក" ទទួលបាន "សំណើរួមរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សុំការពិចារណាឡើងវិញលើការវាយតម្លៃរបស់អង្គបុរេជំនុំជម្រះលើឋានានុក្រមគតិយុត្តនៃវិធានផ្ទៃក្នុង ក្នុងសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ **នួន ជា** ជំទាស់នឹងដីកាបដិសេធសំណើសុំមោឃភាព" ("សំណើសុំការពិចារណាឡើងវិញ")។ សំណើសុំការពិចារណាឡើងវិញនេះ បានដាក់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨។

## **ជំពូក ១ - ប្រវត្តិនីតិវិធី**

២. នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សំណើសុំការពិចារណាឡើងវិញ។

៣. នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីសង្កេតរបស់ខ្លួនចំពោះសំណើសុំការពិចារណាឡើងវិញរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

៤. នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ សហមេធាវីការពារក្ដីរបស់ជនត្រូវចោទ ("ក្រុមមេធាវីការពារក្ដី") បានដាក់សារណារបស់ខ្លួនឆ្លើយតបទៅនឹងសំណើសុំការពិចារណាឡើងវិញ។

## **ជំពូក ២ - សេចក្ដីសន្និដ្ឋានរបស់ភាគី**

៥. សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំអង្គបុរេជំនុំជម្រះ (១) ពិចារណាឡើងវិញនូវការសម្រេចរបស់អង្គបុរេជំនុំជម្រះ ស្ដីពីទំនាក់ទំនងរវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក **នួន ជា** ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ និង (២) ក្នុងករណីដែលវិធានផ្ទៃក្នុងនៅតែមានសុពលភាព សូមអង្គបុរេជំនុំជម្រះសម្រេចទៅតាមបទប្បញ្ញត្តិនៃច្បាប់ដែលពាក់ព័ន្ធ ដែលក្នុងនោះក្រមនីតិវិធីព្រហ្មទណ្ឌមានអទិភាពជាវិធានផ្ទៃក្នុង ក្នុងករណីដែល

លិខិតូបករណ៍ទាំងពីរនេះ មានភាពមិនសមស្រប ឬខុសគ្នា។"[១] សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា៖

> "សំណើសុំនេះធ្វើឡើងតែចំពោះសេចក្តីសម្រេចរបស់អបជ[អង្គបុរេជំនុំជម្រះ]ដែលទាក់ទងទៅនឹង៖
>
> (i) ការចាត់ទុកវិធានផ្ទៃក្នុងជាច្បាប់នីតិវិធី
>
> (ii) ទំនាក់ទំនងវិធានផ្ទៃក្នុងជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង
>
> (iii) សេចក្តីសន្និដ្ឋានថា វិធានផ្ទៃក្នុងជាលិខិតូបករណ៍គោល ក្នុងករណីមានភាពខុសគ្នារវាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង។
>
> សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាលើសេចក្តីសម្រេចទាំងមូលឡើងវិញទេ។"[២]

៦. សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ការពិចារណាឡើងវិញគឺជាចំណាត់ការសមស្រប និងចាំបាច់បំផុតចំពោះសំណើនេះ ដោយហេតុថា៖

> "(i) ភាគីមួយមិនបានដាក់សារណាតបលើខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍ [ហើយ]
>
> (ii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះជះឥទ្ធិពលយ៉ាងខ្លាំងលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបង្ហាញឱ្យឃើញពីចំណាត់ការជាមូលដ្ឋាននៃកិច្ចដំណើរការនីតិវិធីទាំងមូល ជាពិសេសគឺការបកស្រាយទំនាក់ទំនងជាទូទៅរវាងវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។"[៣]

៧. សហព្រះរាជអាជ្ញាសន្និដ្ឋានថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៅក្នុងដំណើរការនីតិវិធី ប៉ុន្តែពួកគាត់មិនបានលើកសម្អាង ឬដាក់សារណារបស់ខ្លួននោះទេ។

---

[១] សំណើរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំការពិចារណាឡើងវិញលើការវាយតម្លៃរបស់អង្គបុរេជំនុំជម្រះលើឋានានុក្រមគតិយុត្តនៃវិធានផ្ទៃក្នុង ក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ **នួន ជា** ជំទាស់នឹងដីកាបដិសេធសំណើសុំមោឃភាព ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ D55/I/9 ("សំណើសុំការពិចារណាឡើងវិញ") ទំព័រទី ១២។

[២] សំណើសុំការពិចារណាឡើងវិញ ទំព័រទី ៩។

[៣] សំណើសុំការពិចារណាឡើងវិញ ទំព័រទី ៨។

00284522



សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គបុរេជំនុំជម្រះមិនគួរពិចារណាលើអញ្ញត្រកម្មប្រតិសកម្ម របស់ភាគីទាំងនោះ ដែលខ្លួនខកខានមិនបានចូលរួមក្នុងដំណើរការនីតិវិធី ប៉ុន្តែបែរជាមកស្វែងរកការដោះស្រាយ នៅពេលសេចក្តីសម្រេចចុងក្រោយត្រូវបានធ្វើរួចហើយ។[៤] សហព្រះរាជអាជ្ញាបន្ថែមទៀតថា សំណើសុំមិនបានបំពេញតាមលក្ខខណ្ឌសុំឱ្យមានការពិចារណាឡើងវិញលើសេចក្តីសម្រេចនោះទេ។ សំណើសុំ (ក) មិនបានបញ្ជាក់កាលៈទេសៈប្រែប្រួលនៃអង្គហេតុ (ខ) មិនបានបង្ហាញថា សេចក្តីសម្រេចមានកំហុស (គ) មិនបានបង្ហាញថា សេចក្តីសម្រេចបណ្តាលឱ្យមានភាពអយុត្តិធម៌ទេ”[៥]។

៨. នៅក្នុងសារណាតបរបស់ខ្លួន ក្រុមមេធាវីការពារក្តីបានយោងលើសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី លើបញ្ហាស្តីពីការទទួលយកសំណើសុំការពិចារណាឡើងវិញ។[៦] ក្រុមមេធាវីការពារក្តីបន្ថែមទៀតថា អង្គបុរេជំនុំជម្រះគួរកែតម្រូវសាលដីការបស់ខ្លួនដែលបានសម្រេចកាលពីលើកមុន ឱ្យស្របទៅតាមជំហរដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឡើង ឬក៏យកបញ្ហានេះដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធ្វើការសម្រេចតាមផ្លូវច្បាប់។

## ជំពូក ៣ - សេចក្តីពិចារណា

៩. នៅក្នុង “សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង”, អង្គបុរេជំនុំជម្រះបានសម្រេចថា ពាក្យសុំពិចារណាសារជាថ្មីនេះ “អាចទទួលយកបាន ប្រសិនបើមានមូលដ្ឋានស្របច្បាប់ដាក់ជូនអង្គបុរេជំនុំជម្រះ ដើម្បីឱ្យធ្វើការពិចារណាសេចក្តីសម្រេចរបស់ខ្លួន កាលពីលើកមុន។”[៧]

---

[៤] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាស្តីពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យមានការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចលើមោឃភាពនៃបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨ D55/I/10 (“សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា”) វាក្យខណ្ឌទី ២(ក)។

[៥] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា D55/I/10 វាក្យខណ្ឌទី ២(ខ)។

[៦] សារណាឆ្លើយតបទៅនឹងសំណើរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំការពិចារណាសាលដីកាសម្រេចអំពីមោឃភាពជាថ្មី ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ D55/I/11 (“សារណាតបរបស់ក្រុមមេធាវីការពារក្តី”) វាក្យខណ្ឌទី ៤។

[៧] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០៣) សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ C22/I/68 (សេចក្តីសម្រេចចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨) វាក្យខណ្ឌទី ២៥។

អង្គបុរេជំនុំជម្រះបានរកឃើញទៀតថា យោងតាមយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិនានា អង្គបុរេជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិក្នុងការពិចារណាសេចក្តីសម្រេច ដែលខ្លួនបានចេញកាលពីលើកមុន សារជាថ្មី តែការពិចារណាសារជាថ្មីនេះ មិនមែនដោយសារមានកាលៈទេសៈប្រែប្រួលប៉ុណ្ណោះនោះទេ គឺអាចដោយសារនៅពេលដែលខ្លួនយល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬបណ្តាលឱ្យមានភាពអយុត្តិធម៌”[៨]

១០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនបានស្នើសុំអង្គបុរេជំនុំជម្រះ ឱ្យធ្វើការពិចារណាសេចក្តីសន្និដ្ឋាននៃសាលដីកាលើពាក្យសុំមោឃភាពទាំងមូលនោះទេ។ ប៉ុន្តែ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំអង្គបុរេជំនុំជម្រះកែតម្រូវសម្អាងហេតុលើអង្គច្បាប់។ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនបានផ្តល់ទឡ្ហីករណ៍តវ៉ាថា សាលដីកានេះមានកំហុស ឬមានភាពអយុត្តិធម៌ទេ។ ផ្ទុយមកវិញ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋាននៃសាលដីកាលើពាក្យសុំមោឃភាព។

១១. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានាស្តីពីបញ្ហានៃការពិចារណាឡើងវិញនេះ គឺពាក់ព័ន្ធនឹងការពិចារណាឡើងវិញលើសេចក្តីសម្រេចនៃសាលដីកាតែប៉ុណ្ណោះ។ គោលការណ៍*អាជ្ញាអស់ជំនុំ* គឺជាមូលដ្ឋាននៃការពិចារណាឡើងវិញលើសេចក្តីសម្រេចនៃសាលដីកា។ គោលការណ៍នេះ មានអានុភាពអនុវត្តលើសាលដីកាដែលមានកំហុស ឬអយុត្តធម៌ ដែលសាលដីកានេះ បានបិទផ្លូវតវ៉ា ឬសើរើ។ សម្អាងហេតុនៅក្នុងសាលដីកា មិនស្ថិតនៅក្រោមគោលគារណ៍ *អាជ្ញាអស់ជំនុំ*[៩] នោះទេ ពីព្រោះសម្អាងហេតុមិនមានអានុភាពអនុវត្ត ឡើយ។

---

[៨] សេចក្តីសម្រេចចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ វាក្យខណ្ឌទី ២៥។

[៩] Ian Scobbie, *Res Judicata, Precedent and the International Court: A Preliminary Sketch*, 20 Australian Yearbook of International Law, 2000, p. 299; *Barcelona Transaction* case (Belgium v Spain) second phase, *Separate Opinion of Judge Gros*, ICJ Reports, 1970, p. 267.

00284524

D55/I/13



១២. អង្គបុរេជំនុំជម្រះបានសម្រេចលើអង្គសេចក្ដី និងបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងគ្រប់រឿងក្ដី។ ដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណី អនុញ្ញាតឱ្យលើកបញ្ហានៃការអនុវត្តវិធានផ្ទៃក្នុង ក្នុងករណីដែលខ្លួនយល់ឃើញថាចាំបាច់។

១៣. សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មិនបានបង្ហាញថា សាលដីកាលើពាក្យសុំមោឃភាព ពិតជាមានកំហុស ឬនាំដល់ភាពអយុត្តិធម៌។ អាស្រ័យហេតុនេះ សំណើនេះត្រូវបានបដិសេធចោល ក្រោយពីបានពិចារណាចំនុចនានា ដូចដែលបានលើកឡើងខាងលើ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ:**

បដិសេធចោលសំណើសុំការពិចារណាឡើងវិញ ដែលដាក់ជូនដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ៗល។

**ភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **ន័យ ចុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គីមសាន**